Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយបន្ទាន់

# លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និង មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការធនធានទឹកមេគង្គ-ឡានឆាង ចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MoU) លើកទីមួយ សម្រាប់ការគ្រប់គ្រងទន្លេមេគង្គឲ្យបានកាន់តែប្រសើរ

**ទីក្រុងប៉េកាំង ប្រទេសចិន ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ –** ការផ្លាស់ប្តូរទិន្នន័យ និងព័ត៌មាន ការពិនិត្យតាមដានអាងទន្លេ និងការវាយតម្លៃរួមគ្នាលើធនធានទឹកទន្លេមេគង្គ និងធនធានពាក់ព័ន្ធដទៃទៀត គឺជាសកម្មភាពសំខាន់ៗ ដែលនឹងទទួលបានពីភាពជាដៃគូរវាងលេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ (ដែលហៅកាត់ថា MRCS) និងមជ្ឈមណ្ឌលសហប្រតិបត្តិការធនធានទឹកមេគង្គ-ឡានឆាង (LMC Water Center)។

កិច្ចសហប្រតិបត្តិការបច្ចេកទេស រវាង MRCS និង LMC Water Center បានលេចចេញជារូបរាងកាលពីម្សិលមិញ ខណៈដែលភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងមួយ ដើម្បីបញ្ជាក់ពីចំណងសម្ព័ន្ធភាពជាផ្លូវការ។

អនុស្សរណៈនេះ ត្រូវបានត្រូវបានចុះហត្ថលេខាដោយលោកបណ្ឌិត អាន ពេជ្រហត្ថដា នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC និងលោកបណ្ឌិត ចុង យុង (Dr. Zhong Yong) អគ្គលេខាធិការ LMC Water Center នៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីកិច្ចសហប្រតិបត្តិការធនធានទឹកមេគង្គ-ឡានឆាង នៅទីក្រុងប៉េកាំង ដោយរួមមានវត្តមានរដ្ឋមន្ត្រីក្រសួងធនធានទឹក និងបរិស្ថាន មកពីបណ្តាលប្រទេសតាមដងទន្លេមេគង្គ-ឡានឆាងទាំង៦។

លោកបណ្ឌិត ហត្ថដា បានលើកឡើងថា "អនុស្សរណៈនេះ តំណាងឲ្យកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់យើង ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងប្រទេសចិន និងប្រទេសតាមដងទន្លេមេគង្គក្រោម នៅពេលដែលយើងស្វែងរកឲ្យមានការគ្រប់គ្រងអាងទន្លេមេគង្គលើ-ក្រោម ប្រកបដោយប្រសិទ្ធិភាព សម្រាប់ផលប្រយោជន៍រួម និងនិរន្តរភាពនាពេលអនាគត។"

ក្នុងរយៈពេល៥ឆ្នាំខាងមុខនេះ ភាគីទាំងពីរនឹងធ្វើការរួមគ្នាតាមរយៈការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក និងធនធានពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចប្រកបដោយចីរភាព សម្រាប់ប្រទេសតាមអាងទន្លេមេគង្គ។

គោលដៅសកម្មភាពបច្ចេកទេសសម្រាប់កិច្ចសហប្រតិបត្តិការទាំងនេះ រួមមានការចែករំលែកបទពិសោធន៍ ការផ្លាស់ប្តូរទិន្នន័យ និងព័ត៌មាន ការពិនិត្យតាមដានអាងទន្លេ ការសិក្សា និងវាយតម្លៃរួមគ្នា ការគ្រប់គ្រងចំណេះដឹង ព្រមទាំងការកសាងសមត្ថភាពជំនាញពាក់ព័ន្ធ។

លោកបណ្ឌិត ចុង បានមានប្រសាសន៍ថា “ខ្ញុំជឿជាក់ថា អនុស្សរណៈនេះ នឹងធ្វើឲ្យទំនាក់ទំនងរវាងមជ្ឈមណ្ឌលរបស់យើង និងលេខាធិការដ្ឋានMRC កាន់តែជិតស្និតជាងមុន និងបង្កើតនូវសហថាមពលក្នុងកិច្ចសហប្រតិបត្តិការធនធានទឹកក្នុងតំបន់។ វាក៏នឹងជួយយើងក្នុងការចូលរួមចំណែកអភិវឌ្ឍការរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅក្នុងអាងទន្លេមេគង្គ-ឡានឆាងឲ្យបានកាន់តែប្រសើរ។”

នៅក្នុងជំហានដំបូង ភាគីទាំងពីរបានយល់ព្រមរៀបចំធ្វើការស្រាវជ្រាវរួមគ្នាមួយ លើគ្រោះរាំងស្ងួតឆ្នាំ២០១៩ និងស្ថានភាពលំហូរទឹកទាបតាមអាងទន្លេមេគង្គ ដោយការសិក្សានេះនឹងគ្របដណ្តប់ទាំងអាងទន្លេមេគង្គក្រោម និងអាងទន្លេមេគង្គលើក្នុងប្រទេសចិន ដែលតំបន់នេះ ទន្លេមេគង្គត្រូវបានគេស្គាល់ថាជាទន្លេឡានឆាង។

ការស្រាវជ្រាវរួមគ្នា ដែលនឹងចាប់ផ្តើមនៅដើមខែមករា និងបញ្ចប់នៅខែកញ្ញាឆ្នាំ២០២០ មានគោលបំណងកំណត់នូវមូលហេតុ និងផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងស្ថានភាពលំហូរទឹកទាបនៅក្នុងឆ្នាំ២០១៩។

ដោយផ្អែកលើលទ្ធផលដែលកើតចេញពីការសិក្សានេះ គេរំពឹងថានឹងមានការផ្តល់នូវវិធានអនុសាសន៍ និងសកម្មភាពនានាពាក់ព័ន្ធនឹងការចែករំលែកទិន្នន័យ និងព័ត៌មាន និងធ្វើឲ្យកិច្ចការនេះកាន់តែប្រសើរឡើងក្នុងបណ្តាប្រទេសតាមអាងទន្លេ។ ការសិក្សានេះ ក៏នឹងផ្តល់នូវរបៀបរៀបចំពិធីការទំនាក់ទំនងឲ្យបានច្បាស់លាស់ និងពង្រឹងប្រតិបត្តិការនានាលើអាងស្តុកទឹកទាំងនៅក្នុងប្រទេសចិន និងតាមបណ្តាលប្រទេសទន្លេមេគង្គប្រកបដោយភាពសម្របសម្រួល សម្រាប់ធ្វើការឆ្លើយតបឲ្យមានប្រសិទ្ធិភាពទៅនឹងបញ្ហាគ្រោះរាំងស្ងួត និងលំហូរទឹកនាពេលបច្ចុប្បន្ន ក៏ដូចជានាពេលអនាគត។

យោងតាមលទ្ធផលការពិនិត្យតាមដានលំហូរទឹករបស់ MRCចុងក្រោយបំផុតបានបង្ហាញថា គ្រោះរាំងស្ងួតឆ្នាំ២០១៩ បានបណ្តាលឲ្យកម្រិតទឹកទន្លេមេគង្គធ្លាក់ដល់កម្រិតទាបបំផុតនៅក្នុងប្រវត្តិសាស្ត្រ ឬក្នុងកំឡុងពេល៦០ឆ្នាំចុងក្រោយនេះ។ តំបន់ភាគច្រើនតាមអាងទន្លេ កំពុងជួបប្រទះនូវលំហូរទឹកទាបគួរឲ្យកត់សម្គាល់ ចាប់តាំងពីខែមិថុនាមក។

លទ្ធផលបានបង្ហាញបន្ថែមថា លំហូរទឹកទាបខ្លាំង ការធ្លាក់ចុះឃើតនៃសារជាតុកករ និងវត្តមានសារាយឬស្លែនៅលើដីខ្សាច់ និងស្រទាប់បាតទន្លេ គឺជាមូលហេតុដែលបណ្តាលឲ្យពណ៌ទឹកទន្លេមេគង្គប្រែជាពណ៌ខៀវបៃតងនាពេលថ្មីៗនេះ។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
លោក មាស សុភក្រ្ត
មន្ត្រីទំនាក់ទំនងជាមួយអ្នកសារព័ត៌មាន
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល៖ sopheak@mrcmekong.org

###